

unicef
for every child

# បទពិសោធន៍របស់យូនីសេហ្វក្នុងការអនុវត្តអភិក្រមថ្មី ក្នុងការគាំទ្រដល់អភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងរួមចំណែកដល់ការសម្រេចគោលដៅអភិវឌ្ឍន៍មូលធនមនុស្សនៃយុទ្ធសាស្រ្តបញ្ចកោណ

# ដំណាក់កាលទី១ និង ការឆ្លើយតបសកម្មភាពមនុស្សធម៌ទាក់ទងនឹងជម្លោះព្រំដែន

*សន្និបាតក្រសួងមហាផ្ទៃ*

*ភ្នំពេញ ថ្ងៃទី ៤ - ៥ ខែកុម្ភៈ ឆ្នាំ ២០២៦*

# មាតិកានៃបទបង្ហាញ

unicef
for every child



- គោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- អភិក្រមថ្មីរបស់ យូនីសេហ្វក្នុងការគាំទ្រដល់អភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ
- វឌ្ឍនភាពដែលសម្រេចបាន
- របៀបរបបធ្វើការជាមួយដៃគូថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការឆ្លើយតបនិងការផ្តល់ជំនួយមនុស្សធម៌របស់យូនីសេហ្វក្នុងគ្រោះមហន្តរាយនៃជម្លោះព្រំដែន
- ជំហានបន្ទាប់

# ១. គោលបំណងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ



©UNICEF Cambodia/2015/Giacomo Pirozzi

- ✓ បង្ខិតអ្នកផ្តល់សេវាឱ្យកាន់តែជិតកៀកនឹងប្រជាពលរដ្ឋ
- ✓ រដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ រួមទាំងសមត្ថភាពដើម្បីចាត់ចែងនិងផ្តល់សេវាសាធារណៈ
- ✓ តួនាទីរដ្ឋាភិបាលថ្នាក់កណ្តាលផ្លាស់ប្តូរពីការផ្តល់សេវាទៅជាការតម្រង់ទិស និងការកសាងសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីផ្តល់សេវាសាធារណៈជំនួសថ្នាក់ជាតិ

បច្ចុប្បន្នភាព៖

- ✓ មុខងារ ៥៥ បានផ្ទេរទៅក្រុងស្រុកខណ្ឌ ការគ្រប់គ្រងសេវាសុខាភិបាល និងមណ្ឌលកុមារកំព្រាទៅរាជធានីខេត្ត + មុខងារអាណត្តិទូទៅ មុខងារជាជម្រើសផង
- ✓ ធនធានហិរញ្ញវត្ថុនិងសមត្ថភាពកើនឡើងជាបន្តបន្ទាប់

# ២. អនុក្រមថ្មីរបស់ យូនីសេហ្វក្នុងការគាំទ្រដល់អភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ



©UNICEF Cambodia/2018/Fani

- កំណែទម្រង់ជួបបញ្ហាប្រឈមដូចជាវិសមាភាពសមត្ថភាពរវាងខេត្ត ក្រុង ស្រុក និងឃុំសង្កាត់ និង ថវិកាមិនទាន់ស៊ីសង្វាក់គ្នានឹងមុខងារ។
- យូនីសេហ្វផ្តោតលើការពង្រឹងអភិបាលកិច្ចថ្នាក់ខេត្ត ជារដ្ឋបាលថ្នាក់ក្រោមជាតិខ្ពស់ជាងគេ រំពឹងថាខេត្តនឹងបន្តគាំទ្រដល់ការរដ្ឋបាលថ្នាក់ក្រោម។
- ខេត្តមានដែលមានសមត្ថភាពអនុវត្តផែនការ និងថវិកាដោយផ្អែកលើភស្តុតាង ផ្តោយលើលទ្ធផល មានបរិយាបន្ននិងសមធម៌ និងនឹងអាចពង្រឹងក្រុង ស្រុក និងឃុំសង្កាត់បានល្អ។
- យូនីសេហ្វនឹងចូលរួមសាងប្រព័ន្ធសម្របស្រួល និងការលើកកម្ពស់ការចូលរួមរបស់យុវជននិងសហគមន៍ ដែលនឹងផ្តល់បទពិសោធន៍សម្រាប់ការសន្ទនានិងការរៀបចំគោលនយោបាយពាក់ព័ន្ធ

# ២. អនុក្រមថ្មីរបស់ យូនីសេហ្វក្នុងការគាំទ្រដល់អភិបាលកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ (ត)



©UNICEF Cambodia/2018/Todd Brown

## *គោលបំណងជាក់លាក់៖*

- *លើកកម្ពស់ភាពជាអ្នកដឹកនាំនិងភាពជាម្ចាស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការក្នុងការសម្រេចបាននូវសិទ្ធិកុមារ។*
- *ពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចាត់ចែងនិងគ្រប់គ្រងមុខងារសេវាសង្គមដែលបានផ្ទេរ និងប្រគល់ជូនប្រកបដោយគុណភាព*
- *រដ្ឋបាលថ្នាក់ក្រោមជាតិវិភាជន៍ថវិកា និងការប្រើប្រាស់សម្រាប់សេវាសង្គមឆ្លើយតបនឹងតម្រូវការស្ត្រី កុមារ និងយុវជន*
- *ឧបសគ្គដែលរារាំងក្នុងការទទួលបានសេវាសង្គមនៅថ្នាក់ក្រោមជាតិត្រូវបានកាត់បន្ថយ។ (ការផ្លាស់ប្តូរឥរិយាបទ និងការចូលរួមសហគមន៍)*

# ៣. វឌ្ឍនភាពសម្រេចបាន



©UNICEF Cambodia/2015/Giacomo Pirozzi

- ផែនការនិងកម្មវិធីវិនិយោគ៖ ៣/៣ លើកគម្រោងពាក់ព័ន្ធនឹងសិទ្ធិកុមារ និង x/៣ វិភាជន៍ថវិកាតាមលិខិតណែនាំ
- សមត្ថភាពក្នុងការគ្រប់គ្រងអនុវត្តន៍មុខងារ និងធនធានដែលបានផ្ទេរ៖ ការនុវត្ត RBM ការអនុលោមតាមគោលការណ៍ណែនាំសម្រាប់ការរៀបចំផែនការថវិកា (TBC) និងការអនុវត្ត (កម្មវិធី និងឧបករណ៍គ្រប់គ្រង ២/៣)
- ក្រុងស្រុកនៅខេត្ត ២/៣ មានកិច្ចសន្ទនាជាមួយយុវជនក្នុងការលើកកម្ពស់អភិបាលកិច្ចបែបកុមារមេត្រី
- មេរៀនបទពិសោធន៍ពីការងារ (ការបណ្តុះបណ្តាល ការរៀបចំផែនការនិងថវិកា) និងការអនុវត្តនៅថ្នាក់ក្រោមជាតិជាព័ត៌មាននិងភស្តុតាង សម្រាប់គោលនយោបាយនិងពង្រីកកម្មវិធី

# ៤. ដំណើរការអនុវត្ត – តើយើងធ្វើការយ៉ាងដូចម្តេច?
## ៤.១ របៀបធ្វើការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ

- ចូលរួមក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ (ខែមករា-មេសា)៖ គាំទ្រដល់ការប្រើប្រាស់ទិន្នន័យ និងភស្តុតាង ដើម្បីផ្តល់អាទិភាពដល់គម្រោងទាក់ទងនឹងសិទ្ធិកុមារសម្រាប់កម្មវិធីវិនិយោគ។

- ចូលរួមក្នុងដំណើរការរៀបចំថវិកា (ខែឧសភា-សីហា ដល់ខែវិច្ឆិកា សម្រាប់ថ្នាក់ឃុំសង្កាត់)៖ ការផ្តល់ធាតុចូលបច្ចេកទេស រួមទាំងសិក្ខាសាលាមុនការរៀបចំថវិកា ដើម្បីពង្រឹងការរៀបចំថវិកាដែលផ្តោតលើកុមារ និងសមធម៌។

- ក្រសួងស្ថាប័នថ្នាក់ជាតិចូលរួមព្រឹត្តិការណ៍រៀបចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងលើកកម្ពស់ការផ្សារភ្ជាប់ផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងគោលនយោបាយជាតិ

- ការគាំទ្រដំណើរការនៃការរៀបចំផែនការសកម្មភាពតាមវិស័យ និងអន្តរវិស័យ ឧ...ផែនការអភិវឌ្ឍកុមារតូច

- ទស្សនកិច្ច និងការចូលរួមក្នុងសន្និបាតថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីចែករំលែកលទ្ធផល មេរៀន និងការអនុវត្តល្អៗ ដែលទទួលបានពីការអនុវត្ត

# ៤. ដំណើរការអនុវត្ត – តើយើងធ្វើការយ៉ាងដូចម្តេច?
# ៤.២ ការកសាងសមត្ថភាពលើការគ្រប់គ្រងដោយផ្តោតលើលទ្ធផល

- ការអភិវឌ្ឍរួមគ្នានូវសម្ភារៈបណ្តុះបណ្តាល
- បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ - បណ្តុះបណ្តាលបន្តដល់ថ្នាក់ខេត្ត និងការអនុវត្តជាក់ស្តែង។
- ក្រុមគ្រូបង្គោលថ្នាក់ជាតិ បានពិនិត្យកែសម្រួលសម្ភារៈបណ្តុះបណ្តាល ដើម្បីធានាបាននូវភាពសមស្របនឹងបរិបទរបស់កម្ពុជារួមទាំងការប្តេជ្ញាចិត្តក្នុងការបញ្ចូលខ្លឹមសារក្នុងសេចក្តីណែនាំបច្ចេកទេស កម្មវិធីបណ្តុះបណ្តាល និងវគ្គរៀនសូត្រនានា។
- NASLA គឺជាដៃគូសក្តានុពលក្នុងការផ្សព្វផ្សាយចំណេះដឹង និងការអនុវត្ត RBM
- ក្រុមនិស្សិតសាលាគោលនយោបាយសាធារណៈ លី ក្វាន់យូ (LKY) កំពុងធ្វើ PAE រំពឹងថានឹងផ្តល់នូវគំនិតល្អៗសម្រាប់ការពង្រីកការងារនេះ។

# ៤. ដំណើរការអនុវត្ត – តើយើងធ្វើការយ៉ាងដូចម្តេច?
# ៤.៣ ការអភិវឌ្ឍ ប្រព័ន្ធ និងឧបករណ៍សំខាន់ៗ

- រៀបចំផ្គាំផព័ត៌មានគ្រប់គ្រង និងតាមដានត្រួតពិនិត្យកម្មវិធី
- កម្មវិធីសម្រាប់ការរៀបចំថវិកាឃុំសង្កាត់ ដែលគាំទ្រដល់តម្លាភាព និងគណនេយ្យភាពក្នុងការប្រើប្រាស់ថវិកា;
- ការវិភាគថវិកា និងសេចក្តីសង្ខេបថវិកា ដើម្បីជូនព័ត៌មានភស្តុតាង សម្រាប់ការធ្វើផែនការ និងការធ្វើការសម្រេចចិត្តលើការវិភាជន៍ធនធានប្រកបដោយសមធម៌ និងឆ្លើយតបទៅនឹងតម្រូវការ
- ការគាំទ្រការវាយតម្លៃ និងការកែសម្រួលសេចក្តីណែនាំបច្ចេកទេសសម្រាប់ការរៀវចំផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរួមបញ្ចូលសិទ្ធិកុមារ ការគ្រប់គ្រងផ្អែកលើលទ្ធផល (RBM) និងវិធីសាស្ត្រផ្អែកលើភស្តុតាង។

# ៥. ជំនួយមនុស្សធម៌ដល់អ្នកទទួលរងផលប៉ះពាល់ដោយសារជម្លោះព្រំដែន




ចាប់តាំងពីការចាប់ផ្តើមនៃជម្លោះព្រំដែន យូនីសេហ្វ បានផ្តល់ជំនួយជូនពលរដ្ឋរងផលប៉ះពាល់ រួមទាំងអ្នកដែលរស់នៅក្នុងមណ្ឌលសុវត្ថិភាពក៏ដូចជាអ្នកដែលបានវិលត្រឡប់មកវិញ ឬស្នាក់នៅបន្តក្នុងតំបន់កៀសសិក នូវជំនួយផ្នែកសុខភាព អាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ការអប់រំ កិច្ចការពារកុមារ និងជំនួយគាំពារសង្គម ដោយផ្តោតលើខេត្តបន្ទាយមានជ័យ ឧត្តមានជ័យ និងខេត្តព្រះវិហារ។



## អាហារូបត្ថម្ភ

UNICEF បន្តធ្វើការពិនិត្យមើលរកកុមារដែលមានកង្វះអាហារូបត្ថម្ភស្រួចស្រាវនៅតំបន់កៀសសិក។ ចាប់តាំងពីថ្ងៃទី ៧ ខែធ្នូមក មានកុមារអាយុ 0-៥៩ ខែចំនួន ១១,៨៥១ នាក់ (ក្មេងស្រី ៥,៨៨៨ នាក់ និងក្មេងប្រុស ៥,៩៦៣ នាក់) ត្រូវបានរកឃើញមានកង្វះអាហារូបត្ថម្ភស្រួចស្រាវ។ ចំណែកឪពុកម្តាយដែលបានចូលរួមក្នុងការពិនិត្យនេះ ទទួលបានការអប់រំសុខភាពស្តីពីការកែលម្អការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារបន្ថែម និងការអនុវត្តអនាម័យ។

## សុខភាព

UNICEF, RACHA និងមន្ទីរសុខាភិបាល បានដាក់ពង្រាយក្រុមពេទ្យចល័ត ផ្តល់ការថែទាំផ្ទៃពោះដល់ស្ត្រីមានផ្ទៃពោះ និងការចាក់ថ្នាំបង្ការសម្រាប់កុមារ។ លើសពីនេះ UNICEF បានបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល គ្រូបង្រៀន និងក្រុមគាំទ្រសុខភាពភូមិអំពីការគាំទ្រផ្លូវចិត្ត និងធ្វើការអប់រំសុខភាពដល់សហគមន៍ដែលសរុបមានអ្នកចូលរួមចំនួន ៣៥,៤៣៤ នាក់។




## ការអប់រំ

UNICEF បន្តគាំទ្រឱកាសរៀនទាន់ពេលដល់កុមារអាយុពី ៣ ទៅ ៥ ឆ្នាំដែលរងផលប៉ះពាល់ដោយជម្លោះ។ ចាប់តាំងពីថ្ងៃទី ៧ ខែធ្នូ UNICEF បានគាំទ្រកុមារចំនួន ៤,៦៧៣ នាក់ (ក្មេងស្រី ២,៧០៩ នាក់ និងក្មេងប្រុស ១,៩៦៤ នាក់) ឱ្យទទួលបានការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ រួមទាំងឱកាសរៀនទាន់ពេល និងផ្តល់សម្ភារៈសិក្សាថ្នាក់តំបូងៗដល់កុមារចំនួន ៧១១ នាក់ (ក្មេងស្រី 404 នាក់ និងក្មេងប្រុស 307 នាក់)។

## ទឹកស្អាតនិងអនាម័យ

UNICEF និងដៃគូបានដំឡើងបង្គន់នៅតំបន់កៀសសិកនៅខេត្តឧត្តមានជ័យ និងខេត្តព្រះវិហារ ហើយបានផ្តល់សម្ភារៈទឹកស្អាតនិងអនាម័យ។ ចាប់តាំងពីថ្ងៃទី ៧ ខែធ្នូ UNICEFបានផ្តល់ដល់ពលរដ្ឋចំនួន ៧១,១៤០ នាក់ នូវសម្ភារៈទឹកស្អាតនិងអនាម័យដែលចាំបាច់ ដែលក្នុងនោះរួមមានក្មេងស្រី ១១,១៥៥ នាក់ ក្មេងប្រុស ១១,៦១០ នាក់ ស្ត្រី ២៤,៦៧២ នាក់ និងបុរស ២៣,៧០៣ នាក់។



## គាំពារសង្គម

UNICEFបានគាំទ្រក្រុមជំនួយសង្គមបណ្តោះអាសន្នដែលបានផ្តល់ជំនួយសាច់ប្រាក់ដល់ជនភៀសសិកចំនួន ៤,៤០៣ នាក់ដែលរស់នៅតំបន់ភៀសសិក (ក្មេងស្រី ៤៣៣ នាក់ ក្មេងប្រុស ៤៣៩ នាក់ ស្ត្រី ២,២៥៦ នាក់ និងបុរស ១,២៧៥ នាក់)។ UNICEF ក៏កំពុងធ្វើការជាមួយ មជជ និង MoSAVY ដើម្បីតាមដានស្ថានភាពអ្នកទទួលផលនៃកម្មវិធីកញ្ចប់គ្រួសារនៅតំបន់ភៀសសិក ដើម្បីស្វែងយល់និងកាត់បន្ថយឧបសគ្គដល់អ្នកទទួលផលដែលបានចុះឈ្មោះរួច។

## កិច្ចការពារកុមារ

UNICEF និងដៃគូរបស់ខ្លួនបាននឹងកំពុងគាំទ្រដល់កន្លែងសុវត្ថិភាពកុមារ ផ្តល់កិច្ចការពារកុមារ និងការតស៊ូមតិដើម្បីដោះស្រាយតម្រូវការជាក់លាក់របស់កុមារដែលទាក់ទងនឹងច្បាប់ ផ្តល់ការគាំទ្រផ្នែកចិត្តសង្គមតាមរយៈបុគ្គលិកសង្គម និងព្រះសង្ឃ បណ្តុះបណ្តាលបុគ្គលិកជួរមុខលើប្រធានបទកិច្ចការពារសំខាន់ៗ និងផ្តល់សេវាគ្រប់គ្រងករណីដល់កុមារដែលងាយនឹងរងគ្រោះ ឬជួបបញ្ហាទាក់ទងនឹងកិច្ចការពារ។


unicef
for every child
សូមអរគុណ!
© UNICEF Cambodia/2023/Bunly Meas